00944019

E185/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 08 / 2013
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឲ្យ ទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ Jacques VERGES
Victor KOPPE Anta GUISSE
គង់ សំអុន
Arthur VERCKEN

## ១. សេចក្តីផ្តើម

1. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវបញ្ជីឯកសារចំនួន ៤ ដែលមានឯកសារចំនួន ១៤២ ដែលឯកសារទាំងនោះមានការពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១ និង ទី ២ និងទួលពោធិជ្រៃ[1]។ ភាគីនានាត្រូវបានផ្តល់ឱកាសឱ្យធ្វើការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារទាំងអស់នេះនៅក្នុងសវនាការដែលប្រព្រឹត្តទៅនៅថ្ងៃទី ២១ និងទី ២២ ខែ មករា ឆ្នាំ ២០១៣។ នៅក្នុងពេលសវនាការនេះក្រុមមេធាវីការពារក្តី អៀង សារី បានកំណត់ឯកសារបន្ថែមចំនួន ៣៨ ដែលខ្លួនបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ[2]។ ភាគីនានាក៏ត្រូវបានអនុញ្ញាតផងដែរឱ្យដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងឯកសារដែលនៅសេសសល់[3]។

2. ផ្អែកតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើឯកសារថ្មីៗ ឯកសារបន្ថែមជាច្រើនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលើកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១[4]។ ភាគីនានា

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឱ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការការដេញដោលលើឯកសារ ឯកសារលេខ E223/2/1 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។ ឧបសម្ព័ន្ធ ១៖ ឯកសារដែលនៅសេសសល់ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារលេខ E223/2/1)។ ឧបសម្ព័ន្ធ 2A៖ ឯកសារបន្ថែមរបស់ ក.ស.ព ពាក់ព័ន្ធនឹងដំណាក់កាលទីមួយ - ការជម្លៀសប្រជាជន (ឯកសារលេខ E223/2/1.2)។ ឧបសម្ព័ន្ធ 2B៖ ឯកសារបន្ថែមរបស់ ក.ស.ព ពាក់ព័ន្ធនឹងដំណាក់កាលទីពីរ - ការជម្លៀសប្រជាជន (ឯកសារលេខ E223/2/1.3)។ ឧបសម្ព័ន្ធ 2C៖ ឯកសារបន្ថែមរបស់ ក.ស.ព ពាក់ព័ន្ធនឹងវាលពិឃាដទួលពោធិ៍ជ្រៃ (ឯកសារលេខ E223/2/1.4)។

[2] ទោះបីជាសេចក្តីសម្រេចបច្ចុប្បន្នបានចេញបន្ទាប់ពីការលុបចោលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ក្រោយពីមរណៈភាពរបស់លោកក៏ដោយ ក៏អង្គជំនុំជម្រះ ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ បានពិចារណាលើសេចក្តីសន្និដ្ឋានទាំងអស់ដែលនៅសល់ជាប់ពាក់ព័ន្ធនឹងបញ្ហានានានៅក្នុងពេលជំនុំជម្រះ។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ក្រោយពីអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចនាថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E284 កថាខណ្ឌ ៥៣។

[3] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៦៩។

[4] អង្គជំនុំជម្រះបានសម្រេចលើឯកសារថ្មីៗចំនួនពីរប្រភេទ៖ "ឯកសារថ្មី" មាននៅក្នុងបញ្ជីដំបូងដែលភាគីបានដាក់ស្របតាមវិធាន ៨០(៣)(ឃ) ដោយក្តោបរួមឯកសារនានាដែលកំណត់ដោយភាគីនៅក្នុងពេលចាប់ផ្តើមការជំនុំជម្រះដែលពុំទាន់ដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅពេលអង្គជំនុំជម្រះទទួលបានរឿងក្តី និង (២) ឯកសារដែលមិនមាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះដែលការទទួលយកឯកសារទាំងនេះនៅក្នុងពេលជំនុំជម្រះត្រូវបានស្នើសុំដោយភាគីនានានៅក្នុងពេលជំនុំជម្រះអនុលោមតាវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ *សូមមើល* សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត

ត្រូវបានផ្តល់ឱកាសឲ្យធ្វើការជំទាស់ទៅនឹងឯកសារទាំងអស់នេះ នៅដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរផងដែរ[5]។

3. សេចក្តីសម្រេចនេះដាក់បញ្ចូលនូវរាល់ការជំទាស់ទាំងអស់ដែលបានធ្វើចំពោះឯកសារដែលនៅសេសសល់ និងប្រភេទឯកសារដែលបានស្នើឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២/០១ និងកំណត់ថា តើឯកសារទាំងនោះបំពេញលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបានដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដែលអាចត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែរឬយ៉ាងណា។

## ២. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ឯកសារទាំងឡាយ និងប្រភពផ្សេងៗទៀតដែលត្រូវបានយោងនៅក្នុងលេខយោងជើងទំព័រនៃផ្នែកនានានៃដីកាដំណោះ

---

ឯកសារលេខ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ (“សេចក្តីសម្រេចស្តីពីឯកសារថ្មី”) ជាមួយនឹងឧបសម្ព័ន្ធ។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការដាក់ឯកសារថ្មីចូលទៅក្នុងសំណុំរឿង ឯកសារលេខ E190/2 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២ (“សេចក្តីសម្រេចលើកទីពីរស្តីពីឯកសារថ្មី”) ជាមួយនឹងឧបសម្ព័ន្ធ (ជារួមហៅថា “សេចក្តីសម្រេចស្តីពីឯកសារ”)។ លើសពីនេះ ឯកសារមួយចំនួនផ្សេងទៀតក៏ត្រូវបានដាក់បញ្ចូលនៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមសេចក្តីសម្រេចផ្ទាល់មាត់នានា ឬ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរជាច្រើនពាក់ព័ន្ធនឹងសំណើសុំទទួលយកឯកសារនីមួយៗអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ ឯកសារនានាដែលមាននៅក្នុងសេចក្តីសម្រេចទាំងនេះពុំត្រូវបានវាយតម្លៃនៅក្នុងសេចក្តីសម្រេចបច្ចុប្បន្ននេះឡើយ។

[5] *សូមមើល ឧ.* សវនាការផ្ទាល់មាត់បន្ថែមលើឯកសារ (ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២) ឯកសារលេខ E172/1 ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។ បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្តបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) ឯកសារលេខ E172/5 ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២។ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារលេខ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែប្រែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ ឯកសារលេខ E223/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២។ កាលវិភាគដែលបានកែសម្រួលថ្មី សម្រាប់សវនាការលើឯកសារនាពេលខាងមុខ (ចាប់ផ្តើមពីថ្ងៃចន្ទ ទី ២១ ខែ មករា ឆ្នាំ ២០១៣) ឯកសារលេខ E223/3 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣។ ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់ ឯកសារលេខ E264/1 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ (“សេចក្តីសម្រេចស្តីពីឯកសារថ្មី”)។

ស្រាយដែលពាក់ព័ន្ធទៅនឹងវគ្គសវនាការនីមួយៗនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង[6]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ទៀតថា ឯកសារទាំងអស់នេះ ត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្ត រួមទាំងយថាភាពផងដែរ[7]។

5. ភាគីបានទទួលឱកាសដើម្បីជំទាស់ទៅនឹងការសន្មតដែលពាក់ព័ន្ធនឹងឯកសារដែលត្រូវបានដកស្រង់នៅក្នុងលេខយោងជើងទំព័រនៅផ្នែកស្តីពីប្រវត្តិសាវតារនៃដីកាដំណោះស្រាយនៅក្នុងសវនាការថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ("សវនាការលើកទីមួយលើឯកសារ")[8]។ នៅក្នុងអំឡុងពេលសវនាការ ភាគីក៏តម្រូវឱ្យបង្ហាញការជំទាស់ទៅនឹងឯកសារទាំងអស់ដូចបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ A1-A5 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៨០ ផងដែរ[9]។ នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ សវនាការបន្ថែមមួយទៀតត្រូវបានគ្រោងនឹងធ្វើឡើងដើម្បីផ្តល់ឱកាសឱ្យជំទាស់ពាក់ព័ន្ធនឹងឯកសារដែលត្រូវបានដកស្រង់នៅក្នុងលេខយោងជើងទំព័រក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ទាក់ទិននឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និង

---

[6] *សូមមើល* ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២-៣។ ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២) ឯកសារលេខ E159 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ ("ដីកាកំណត់កាលបរិច្ឆេទលើកទីមួយនៃសវនាការលើឯកសារ") កថាខណ្ឌ ៥។ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ E172 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២។

[7] ប្រតិចារិក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៨៥-៨៨ (ជាភាសាអង់គ្លេស)។ *សូមមើលផងដែរ* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114 E114/1 E131/1/9 E131/6 E136 និង E158 ឯកសារលេខ E162 ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (សេចក្តីសង្ខេបសេចក្តីសម្រេចផ្ទាល់មាត់) កថាខណ្ឌ ៣។

[8] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។

[9] ដីកាកំណត់កាលបរិច្ឆេទលើកទីមួយនៃសវនាការលើឯកសារ។ *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទងទៅនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី ឯកសារលេខ E109/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("បញ្ជីរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១") រួមជាមួយនឹងឧបសម្ព័ន្ធ A1-A20។

ធាតុផ្សំមួយចំនួនទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ ("សវនាការលើកទីពីរលើឯកសារ")[10]។ អង្គជំនុំជម្រះបានសម្រេចលើការជំទាស់ទាំងនេះនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២[11]។ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានកំណត់ឯកសារចំនួនបី (ឯកសារលេខ D366/7.1.72 ឯកសារលេខ D243/2.1.16 និងឯកសារលេខ D366/7.1.820) ដែលត្រូវបានដកចេញដោយភ័ន្តច្រឡំពីក្នុងសេចក្ដីសម្រេចលើឯកសាររបស់អង្គជំនុំជម្រះ។ នៅពេលនេះ ឯកសារទាំងនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

6. នៅចន្លោះថ្ងៃទី ១២ និងថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ភាគីបានទទួលឱកាសដើម្បីជំទាស់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 ដែលនៅសេសសល់របស់សហព្រះរាជអាជ្ញា រួមទាំងឯកសារមួយចំនួនដែលស្នើឡើងដោយភាគីផ្សេងទៀត ("សវនាការលើកទីបីលើឯកសារ") [12]។ អង្គជំនុំជម្រះបានសម្រេចលើការជំទាស់ទាំងនេះនៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២[13]។

---

[10] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) ឯកសារលេខ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៥។

[11] សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារលេខ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចលើឯកសារក្របខណ្ឌ")។

[12] ប្រតិចារឹក ចុះថ្ងៃទី ១២-១៥ ខែ មីនា ឆ្នាំ ២០១២ និងបច្ចុប្បន្នភាពទៅលើអនុស្សារណៈស្ដីពីសវនាការលើឯកសារនៅដំណាក់កាលបន្តបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) ឯកសារលេខ E172/5 ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ២។ សវនាការនេះកម្រិតត្រឹមការដេញដោលលើឯកសារដែលពុំទាន់បានយកមកពិភាក្សានៅក្នុងតុលាការនាពេលមុន ឬ ដែលពុំទាន់បានយកមកពិចារណានៅក្នុងសេចក្ដីសម្រេចលើឯកសារក្របខណ្ឌតែប៉ុណ្ណោះ។ ដោយសារតែឯកសារមួយចំនួនដូចបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ A6-A20 នៃបញ្ជីរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ក៏ត្រូវបានដកស្រង់នៅក្នុងលេខយោងជើងទំព័រនៅក្នុងដីកាដំណោះស្រាយ ការជំទាស់ទៅនឹងឯកសារទាំងនេះត្រូវបានយកមកពិចារណានៅក្នុងសេចក្ដីសម្រេចលើឯកសារក្របខណ្ឌ (*សូមមើល* ឧបសម្ព័ន្ធ A ទៅនឹងសេចក្ដីសម្រេចលើឯកសារក្របខណ្ឌ (ឯកសារលេខ E185.1))។ ការជំទាស់ទៅនឹងឯកសារដូចមាននៅក្នុងឧបសម្ព័ន្ធ A12-13 មិនត្រូវបានយកមកពិចារណានៅក្នុងសវនាការលើកទីបីលើឯកសារ ហើយនឹងមិនត្រូវបានពិចារណានៅក្នុងសេចក្ដីសម្រេចបច្ចុប្បន្ន។ ការជំទាស់ទាំងនេះត្រូវបានសម្រេចនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E96/7 ("សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយ") និងសេចក្ដីសម្រេចដែលគ្រោងនឹងធ្វើឡើងលើការជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សេចក្ដី

7. នៅថ្ងៃទី ៣០ ខែ មេសា និងថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានដាក់ឯកសារថ្មីចំនួន ៤៨៥ នៅក្នុងសំណុំរឿង ដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១ អនុលោមតាមវិធាន ៨០(៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងផ្តល់ឱកាសសម្រាប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារទាំងនេះនៅក្នុងពេលសមស្របខាងមុខ[14]។

8. នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា សវនាការមួយគ្រោងនឹងធ្វើឡើងដើម្បីឱ្យមានការពិភាក្សាដេញដោលពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២/០១ រួមទាំងឯកសារថ្មីទាំងអស់ ("សវនាការលើកទីបួនលើឯកសារ")[15]។ អង្គជំនុំជម្រះក៏បានណែនាំឱ្យភាគីបញ្ជាក់អំពីអត្តសញ្ញាណនៃឯកសារណាខ្លះដែលស្ថិតនៅក្នុងបញ្ជីឯកសារដើម ដែលពួកគេបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងវគ្គជំនុំជម្រះដែលនៅសេសសល់ ដូចជា ការជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២

---

សម្រេចលើកំណត់ហេតុស្តាប់ចម្លើយដែលគ្រោងនឹងចេញ")(*សូមមើល* ឧបសម្ព័ន្ធ IV (ខ)៖ បញ្ជីស្តីពីញត្តិទាំងអស់ដែលបានដាក់នៅក្នុងពេលជំនុំជម្រះ និងសេចក្តីសម្រេចឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងញត្តិទាំងនេះ (ញត្តិទាំងនេះនៅរង់ចាំសេចក្តីសម្រេចនៅចំពោះមុខអង្គជំនុំជម្រះ (ដែលសេចក្តីសម្រេចនេះសង្ឃឹមថានឹងចេញក្នុងពេលឆាប់ៗ) ទំព័រ ២៦ (ជាភាសាអង់គ្លេស) (ត្រូវបានបញ្ជូលទៅភាគីទាំងអស់ដើម្បីជាការជូនដំណឹងពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣)។

[13] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារលេខ E185/1 ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើកទីពីរលើឯកសារ")។ ឧបសម្ព័ន្ធ ២១ រួមមានបញ្ជីឯកសារដែលមិនមាននៅក្នុងសំណុំរឿងដែលត្រូវបានដាក់នៅដើមដំណាក់កាលនៃការជំនុំជម្រះ។ ឯកសារនានាដែលបានដាក់នៅក្នុងឧបសម្ព័ន្ធនោះក៏ដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ A1-A20 នៃបញ្ជីរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ឯកសារទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងអនុលោមតាមសេចក្តីសម្រេចលើឯកសារថ្មីប៉ុន្តែមិនត្រូវបានសម្រេចនៅក្នុងសេចក្តីសម្រេចលើឯកសារគ្រប់ខណ្ឌ ឬ នៅក្នុងសេចក្តីសម្រេចលើកទីពីរលើឯកសារនោះទេ។

[14] សេចក្តីសម្រេចលើឯកសារថ្មី *សូមមើលផងដែរ* សេចក្តីសម្រេចលើកទីពីរលើឯកសារ កថាខណ្ឌ ២២។

[15] នៅក្នុងចំណោមឯកសារថ្មីដំបូងចំនួន ៤៨៥ នៅក្នុងសេចក្តីសម្រេចលើឯកសារថ្មី ការទទួលយកឯកសារ ៤៥១ នេះពុំទាន់បានសម្រេចដោយអង្គជំនុំជម្រះនៅឡើយទេ។ សេចក្តីសម្រេចភ្លាមៗនេះសម្រេចលើការជំទាស់ទាំងអស់ទៅនឹងឯកសារ។ ឯកសារនៅសល់ចំនួន ៥០ ទៀត បានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនៅក្នុងដំណាក់ការនីតិវិធីជំនុំជម្រះ ឬ ត្រូវបានសម្រេចរួចហើយនៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយដែលកំពុងរង់ចាំសម្រេច។

និងទួលពោធិ៍ជ្រៃ[16] មិនឲ្យលើសពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២។ សហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២[17]។

9. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សវនាការលើកទីបួនលើឯកសារ នឹងធ្វើឡើងនៅក្នុងអំឡុងសប្តាហ៍ថ្ងៃទី ១៨ ដល់ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣[18]។ ដោយសារតែអង្គជំនុំជម្រះពុំអាចបន្តស្តាប់សក្ខីកម្មរបស់សាក្សីបានដោយមូលហេតុជនជាប់ចោទបន្តមានបញ្ហាសុខភាព សវនាការលើឯកសារនេះត្រូវបានលើកមកធ្វើមុនកាលកំណត់នៅចន្លោះថ្ងៃទី ២១ ដល់ ថ្ងៃទី ២៤ និងថ្ងៃទី ៣០ ដល់ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ វិញ[19]។

10. នៅមុនពេលចាប់ផ្តើមសវនាការលើកទីបួនលើឯកសារ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារចំនួន ០៤ ដោយនៅពេលនោះឱកាសសម្រាប់ការពិភាក្សាដេញដោលលើភាពអាចទទួលយកបាននៅពុំទាន់បានផ្តល់ឲ្យនៅឡើយទេ ("បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា")។ បញ្ជីឯកសារទីមួយរួមមានឯកសារសំខាន់ៗចំនួន ៤៨ ដែលស្នើសុំដោយភាគីជាច្រើន ខណៈបញ្ជីឯកសារបីទៀតដែលនៅសល់រួមមានឯកសារសរុបចំនួន ៩៤ ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះ

---

[16] សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សារណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារលេខ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទខៀវ សំផន ស្នើសុំកែប្រែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ ឯកសារលេខ E223/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ២-៦។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការការដេញដោលលើឯកសារ ឯកសារលេខ E223/2/1 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[18] ការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញសម្រាប់ដើមឆ្នាំ ២០១៣ ឯកសារលេខ E236/4 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣។

[19] កាលវិភាគដែលបានកែសម្រួលថ្មី សម្រាប់សវនាការលើឯកសារនាពេលខាងមុខ (ចាប់ផ្តើមពីថ្ងៃចន្ទ ទី ២១ ខែ មករា ឆ្នាំ ២០១៣) ឯកសារលេខ E223/3 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ២។ នៅក្នុងអំឡុងពេលសវនាការលើកទីបួនលើឯកសារ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីមានឱកាសគូសបញ្ជាក់ឯកសារគន្លឹះដែលអង្គជំនុំជម្រះចាត់ទុកថាមានសារសំខាន់ខ្លាំងពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រសាវតានៅក្នុងការជំនុំជម្រះវគ្គនេះ (ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៥៥ និងទំព័រ ៦៩-៧១ (ជាភាសាអង់គ្លេស)។ *សូមមើលផងដែរ* ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) ឯកសារលេខ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២-៣។ ឱកាស ដើម្បីគូសបញ្ជាក់អំពីឯកសារគន្លឹះពាក់ព័ន្ធនឹងការជំនុំជម្រះវគ្គនេះក៏បានផ្តល់ឲ្យនៅក្នុងពេលជំនុំជម្រះទាំងមូល។

មុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២ និងទួលពោធិ៍ជ្រៃ[20]។ នៅក្នុងពេលសវនាការនេះ ក្រុមមេធាវីការពារក្តី អៀង សារី បានកំណត់អត្តសញ្ញាណឯកសារចំនួន ៥៤ ដែលពួកគេពិចារណាឃើញថា ពុំមែនជាកម្មវត្ថុនៃការពិភាក្សានោះទេ[21]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ឯកសារទាំងអស់ផ្សេងទៀតដែលរួមមាននៅក្នុងបញ្ជីឯកសារសំណុំរឿង ០០២/០១ របស់ភាគីត្រូវបានពិភាក្សាដេញដោលរួចហើយ រីឯការជំទាស់ទៅនឹងបញ្ជីឯកសារទាំងនេះត្រូវបានសម្រេចដោយអង្គជំនុំជម្រះរួចរាល់ដែរ ចាប់តាំងពីពេលនោះមក[22]។

11. បន្ទាប់ពីធ្វើសវនាការលើកទីបួនលើឯកសាររួចមក ក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារមួយចំនួន[23]។ ក្រុមមេធាវីការពារក្តី នួន ជា បានឆ្លើយតបនៅថ្ងៃទី ០៨

---

[20] ឧបសម្ព័ន្ធ ១៖ ឯកសារដែលនៅសេសសល់ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារលេខ E223/2/1) (រួមមានឯកសារពីរដែលមាននៅក្នុងលេខយោងជើងទំព័រនៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទី I & ដំណាក់កាលទី II និងទួលពោធិ៍ជ្រៃ ឯកសារចំនួន ០៦ ដាក់ដោយសហព្រះរាជអាជ្ញា ឯកសារចំនួនពីស្នើដាក់ដោយសហមេធាវីនាំមុខ ឯកសារចំនួនមួយស្នើដាក់រួមគ្នាដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ឯកសារចំនួន ០៤ ដាក់ដោយក្រុមមេធាវីការពារក្តី អៀង សារី ឯកសារចំនួន ២២ ដាក់ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន និងឯកសារចំនួន ១១ ដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា។ ឧបសម្ព័ន្ធ 2A៖ ឯកសារបន្ថែមរបស់ ក.ស.ព ពាក់ព័ន្ធនឹងដំណាក់កាលទីមួយ - ការជម្លៀសប្រជាជន (ឯកសារលេខ E223/2/1.2) (មានឯកសារ ៨៨)។ ឧបសម្ព័ន្ធ 2B៖ ឯកសារបន្ថែមរបស់ ក.ស.ព ពាក់ព័ន្ធនឹងដំណាក់កាលទីពីរ - ការជម្លៀសប្រជាជន (ឯកសារលេខ E223/2/1.3) (០២ ឯកសារ)។ ឧបសម្ព័ន្ធ 2C៖ ឯកសារបន្ថែមរបស់ ក.ស.ព ពាក់ព័ន្ធនឹងវាលពិឃាដទួលពោធិ៍ជ្រៃ (ឯកសារលេខ E223/2/1.4) (០៤ ឯកសារ)។

[21] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៤២-៤៤ និងទំព័រ ៤៩-៦៨ ("បញ្ជីរបស់ក្រុមមេធាវីការពារក្តី អៀង សារី")។

[22] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៦ (ជាភាសាអង់គ្លេស)។

[23] សេចក្តីជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារមួយចំនួន ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E223/2/2 (សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ អៀង សារី ទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា")។ ឧបសម្ព័ន្ធ ១៖ ការជំទាស់របស់ អៀង សារី ទៅនឹងឯកសារស្នើឡើងដោយ ក.ស.ព នៅក្នុងឯកសារ E223/2/1 (ឯកសារលេខ E223/2/1.2) ឧបសម្ព័ន្ធ ២៖ ការជំទាស់របស់ អៀង សារី ទៅនឹងឯកសារស្នើឡើងដោយ ក.ស.ព នៅក្នុងឯកសារ E223/2/1 (ឯកសារលេខ E223/2/1.3) ឧបសម្ព័ន្ធ ៣៖ ការជំទាស់របស់ អៀង សារី ទៅនឹងឯកសារស្នើឡើងដោយ ក.ស.ព នៅក្នុងឯកសារ E223/2/1 (ឯកសារលេខ E223/2/1.4) ឧបសម្ព័ន្ធ ៤៖ ឯកសារនៅសេសសល់ [មិនមែនជាកំណត់ហេតុស្តាប់ចម្លើយ] ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ [មិនពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី ១ ២ ឬ ទួលពោធិ៍ជ្រៃ] (ឯកសារលេខ E223/2/2.1) ឧបសម្ព័ន្ធ ៥៖ ការជំទាស់របស់ អៀង សារី ទៅនឹងឯកសារស្នើឡើងដោយ ក.ស.ព នៅក្នុងឯកសារ E223/2/1 (ឯកសារលេខ E223/2/1.5)។ សេចក្តីជំទាស់ទៅលើឯកសារពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងទីតាំងទួលពោធិ៍ជ្រៃ (ជាមួយ

ខែ កុម្ភៈ ឆ្នាំ ២០១៣[24]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមទៅនឹងការជំទាស់នីមួយៗរបស់ក្រុមមេធាវីការពារក្តីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣[25]។

12. ក្រោយមក អង្គជំនុំជម្រះបានផ្តល់ឱកាសបន្ថែមមួយទៀតឱ្យដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងឯកសារថ្មីទាំងអស់[26]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងឯកសារទាំងនេះ នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយចោទប្រកាន់ថាខ្លួនមិនមានឱកាសគ្រប់គ្រាន់ដើម្បីរៀបចំការជំទាស់ទៅនឹងឯកសារថ្មីទាំងអស់នេះទេ[27]។ ជាការ

---

នឹងឧបសម្ព័ន្ធ) ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E223/2/4 ("សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ ខៀវ សំផន ទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា")។ សេចក្តីអត្ថាធិប្បាយលើ "ឧបសម្ព័ន្ធ ១ នៅក្នុងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងឯកសារបន្ថែមអំពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំការកំណត់កាលបរិច្ឆេទសវនាការលើឯកសារ" (ឯកសារលេខ E223/2/4.1)។ សេចក្តីអត្ថាធិប្បាយលើ "ឧបសម្ព័ន្ធ 2A នៅក្នុងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងឯកសារបន្ថែមអំពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំការកំណត់កាលបរិច្ឆេទសវនាការលើឯកសារ" (ឯកសារលេខ E223/2/4.2)។ សេចក្តីអត្ថាធិប្បាយលើ "ឧបសម្ព័ន្ធ 2B នៅក្នុងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងឯកសារបន្ថែមអំពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំការកំណត់កាលបរិច្ឆេទសវនាការលើឯកសារ" (ឯកសារលេខ E223/2/4.3)។ សេចក្តីអត្ថាធិប្បាយលើ "ឧបសម្ព័ន្ធ 2C នៅក្នុងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងឯកសារបន្ថែមអំពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំការកំណត់កាលបរិច្ឆេទសវនាការលើឯកសារ" (ឯកសារលេខ E223/2/4.4)។

[24] ចម្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញាចំពោះឯកសាររបស់មេធាវីការពារក្តី ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E223/2/3 ("ចម្លើយតបរបស់ នួន ជា ទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា")។

[25] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ ខៀវ សំផន និង អៀង សារី ពាក់ព័ន្ធនឹងការទទួលយកឯកសារមួយចំនួន ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E223/2/5 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ អៀង សារី និង ខៀវ សំផន")។ អង្គជំនុំជម្រះអនុញ្ញាតឱ្យភាគីដាក់សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ពួកគេរហូតដល់ថ្ងៃ ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ និងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាឆ្លើយតបរហូតដល់ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៦៩ (ជាភាសាអង់គ្លេស))។

[26] ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់ ឯកសារលេខ E246/1 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៤។

[27] សេចក្តីជំទាស់មិនទទួលយកឯកសារថ្មី ឯកសារលេខ E246/1/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សេចក្តីជំទាស់របស់ ខៀវ សំផន មិនទទួលយកឯកសារថ្មី") និងការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារនានាដែលមាននៅក្នុង E190.1 និង E190/2.1 ឯកសារលេខ E223/2/2/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។ ក្រុមមេធាវីការពារក្តី នួន ជា ពុំបានដាក់សេចក្តីជំទាស់។

ឆ្លើយតប សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា ភាគីទាំងអស់បានទទួលឱកាសជាច្រើនក្នុងការជំទាស់ទៅនឹងឯកសារថ្មីនៅក្នុងដំណើរការជំនុំជម្រះទាំងមូល[28]។

## ៣. សារណា

### ៣.១. ការជំទាស់របស់សហព្រះរាជអាជ្ញា

13. សហព្រះរាជអាជ្ញាបានជំទាស់ដោយផ្ទាល់មាត់ទៅនឹងការស្នើសុំដាក់ឯកសារចំនួនប្រាំបីដូចខាងក្រោម៖

i. លិខិតបួនច្បាប់ដាក់ជូនដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ ដោយផ្អែកលើមូលដ្ឋានថា លិខិតទាំងនេះពាក់ព័ន្ធនឹងតួនាទីរបស់ ខៀវ សំផនផងដែរ និងមិនមែនត្រឹមតែទាក់ទងនឹងអត្តចរិតនោះទេ ហើយលិខិតទាំងនេះបានស្នើសុំដោយក្រុមមេធាវីការពារក្តីក្រោយពេលបញ្ចប់កិច្ចស៊ើបសួរ[29]។

ii. ឯកសារលេខ E131/1/13/12 (សៀវភៅបង្ហាញដោយក្រុមមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងបញ្ហានយោបាយបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា) ដោយផ្អែកលើមូលដ្ឋាន នៃភាពពាក់ព័ន្ធ[30]។

---

[28] *សូមមើល ខ.* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់ ខៀវ សំផន ទៅនឹងភាពអាចទទួលយកបាននៃឯកសារថ្មីៗ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារលេខ E246/1/2 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់របស់ ខៀវ សំផន ទៅនឹងឯកសារថ្មី") កថាខណ្ឌ ៤-១២។ លើសពីនេះ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានទទួលពេលវេលាពេញមួយរសៀលដើម្បីធ្វើការសង្កេតពាក់ព័ន្ធនឹងតម្លៃនៃភ័ស្តុតាងឯកសារគន្លឹះដែលដាក់ដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ *សូមមើល* កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និងសំណើ E288/1 ឯកសារលេខ E288/1/1 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៥-៦។ ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦០ (ជាភាសាអង់គ្លេស)។

[29] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២២-២៤ (ដែលជំទាស់ទៅនឹងសក្ខីកម្មរបស់ Philippe JULIAN-GAUFRES គាំទ្រលោក ខៀវ សំផន ឯកសារលេខ E190/2.5 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០។ សក្ខីកម្មរបស់ សំ សុខ (SAM SOK) គាំទ្រលោក ខៀវ សំផន ឯកសារលេខ E190/2.7 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ លិខិតមកពីអតីតរដ្ឋមន្ត្រី Roland Dumas ឯកសារលេខ E190/2.18 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ និងសក្ខីកម្មរបស់ Claude Katz ឯកសារលេខ E190/2.19 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១១)។

[30] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៥-២៦ (ជាភាសាអង់គ្លេស) (ដែលជំទាស់ទៅនឹង Joel Brinkley, "Cambodia's Curse: A Modern History of a Troubled Land" ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E131/1/13/12)។

iii. ឯកសារលេខ E131/1/13.2 និងឯកសារលេខ E131/1/13.10 (អត្ថបទកាសែត និង របាយការណ៍ដាក់ជូនដោយក្រុមមេធាវីការពារក្តី នួន ជា ដែលពិនិត្យលើលក្ខណៈសម្បត្តិ និងនយោបាយរបស់ឥស្សរៈជនកម្ពុជាមួយចំនួន និងភាពតានតឹងផ្នែកនយោបាយបច្ចុប្បន្ន រវាងប្រទេសកម្ពុជា និងប្រទេសថៃ) ដោយផ្អែកលើមូលដ្ឋាននៃភាពពាក់ព័ន្ធ[31]។ និង

iv. ឯកសារលេខ E131/1/13.11 (របាយការណ៍ដាក់ជូនដោយក្រុមមេធាវីការពារក្តី នួន ជា ដែលពិភាក្សាលើផែនការសាងសង់ ក៥) ដោយផ្អែកលើមូលដ្ឋាននៃភាពពាក់ព័ន្ធដូចគ្នា[32]។

14. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានយល់ស្របជាមួយនឹងការជំទាស់របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងឯកសារទាំងនេះ[33]។ ជាការឆ្លើយតប ក្រុមមេធាវីការពារក្តីបានជំទាស់ថា ឯកសារលេខ E131/1/13.11 ដែលមានចំណងជើងថា "ផែនការសាងសង់ ក៥ ឆ្នាំ ១៩៨៧" មានភាពពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ប៉ុន្តែពុំបានលើកឡើងអំពីឯកសារផ្សេងៗទៀតមកបង្ហាញ នៅក្នុងពេលសវនាការនេះឡើយ[34]។

**<u>៣.២. ការជំទាស់របស់ក្រុមមេធាវីការពារក្តី</u>**

15. នៅក្នុងពេលសវនាការលើកទីបួនលើឯកសារ ក្រុមមេធាវីការពារក្តី នួន ជា ពុំបានព្យាយាមជំទាស់ដោយផ្ទាល់មាត់ទៅនឹងឯកសារណាមួយឡើយ[35]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន និងក្រុមមេធាវីការពារក្តី អៀង សារី ជាញឹកញាប់ បានលើកឡើងនូវការជំទាស់ដដែលៗរបស់ខ្លួនពីមុនអំពីការស្នើសុំដាក់ប្រភេទឯកសារជាក់លាក់មួយចំនួន ដោយបានសន្និដ្ឋានដូចខាងក្រោម៖

i. លិខិត អត្ថបទសារព័ត៌មាន សៀវភៅ និងអត្ថបទសិក្សាស្រាវជ្រាវ មិនគួរទទួលយកឡើយ លើកលែងតែឯកសារទាំងនេះមានយថាភាព ជាប់ពាក់ព័ន្ធ នឹងអាចជឿទុកចិត្តបាន

---

[31] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៥-២៦ (ជាភាសាអង់គ្លេស) (ដែលជំទាស់ទៅនឹងអត្ថបទ *Vanity Fair* សរសេរឡើងដោយ T.D. Allman ក្រោមចំណងជើងថា "ការសម្តែងល្ខោនរបស់សព្រះអង្គម្ចាស់ សីហនុ" ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E131/1/13.2 និងទស្សនកិច្ចការងារនៅប្រទេសថៃរបស់នាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន ចុះថ្ងៃទី ៦-៧ ខែ ឧសភា ឆ្នាំ ១៩៩៨ ឯកសារលេខ E131/1/13.10)។

[32] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៥-២៦ (ជាភាសាអង់គ្លេស) (ដែលជំទាស់ទៅនឹងផែនការសំណង់ ក៥ ឆ្នាំ ១៩៨៧ ក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៨៦ ឯកសារលេខ E131/1/13.11)។

[33] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៧ (ជាភាសាអង់គ្លេស)។

[34] ចម្លើយតបរបស់ នួន ជា ទៅនឹងការជំទាស់របស់ ក.ស.ព កថាខណ្ឌ ៣-១១។

[35] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៨ (ជាភាសាអង់គ្លេស)។

ហើយប្រសិនបើអ្នកនិពន្ធ ផលិតករ ឬសាក្សីពាក់ព័ន្ធផ្សេងទៀតមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ[36]។

ii. តម្លៃភស្តុតាងនៃខ្សែវីដេអូមិនអាចវាយតម្លៃបានឡើយក្នុងករណីដែលផលិតករ ឬអ្នកដឹកនាំពុំអាចមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងសំណួរនានា ដែលសួរអំពីប្រធានបទនេះ របៀបថតខ្សែវីដេអូ និងមធ្យោបាយផលិតខ្សែវីដេអូនេះជាដើម[37]។

iii. ឯកសារពីរដ្ឋាភិបាលបរទេស ជាពិសេស ពីប្រទេសបារាំង និងសហរដ្ឋអាមេរិក មិនគួរទទួលយកឡើយ លើកលែងតែអ្នកនិពន្ធអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបាន ដោយហេតុថាប្រទេសទាំងពីរនេះមានការពាក់ព័ន្ធនៅក្នុងកិច្ចការរបស់ប្រទេសកម្ពុជានៅក្នុងអំឡុងពេលពាក់ព័ន្ធ[38]។

iv. ប្រវត្តិរូបរបស់សាក្សី ឡុង នរិន្ទ (LONG Norin) មិនគួរទទួលយកឡើយ ដោយផ្អែកលើមូលដ្ឋានថា សាក្សីនេះបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[39]។

v. ចម្លើយសារភាព ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម មិនអាចទទួលយកបានអនុលោមតាមយុត្តិសាស្ត្រពាក់ព័ន្ធនៅ អ.វ.ត.ក[40]។

vi. របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសនៃការិយាល័យសហចៅក្រមស៊ើបអង្កេតមិនគួរទទួលយកឡើយ ដោយហេតុថារបាយការណ៍ទាំងនេះគ្មានតម្លៃជាភស្តុតាងនោះទេ[41]។

vii. រូបថត លើកលែងតែភាគីមានឱកាសជេញជោលអ្នកថតរូប ឬលើកលែងតែមានសញ្ញាឯករាជ្យស្តីពីភាពអាចទុកចិត្តបានដែលផ្តល់បរិបទចាំបាច់[42]។

viii. ឯកសារនានាដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("មជ្ឈមណ្ឌលឯកសារកម្ពុជា") គួរត្រូវបានសម្រេចមិនទទួលយក ដោយហេតុបញ្ហានៃខ្សែសង្វាក់លើការរក្សា

---

[36] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៣៣-៣៦ (ជាភាសាអង់គ្លេស)។

[37] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៣០ ទំព័រ ៣៤-៣៥ (ជាភាសាអង់គ្លេស)។

[38] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៣១-៣២ (ជាភាសាអង់គ្លេស)។

[39] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៣១ (ជាភាសាអង់គ្លេស)។

[40] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៣១ (ជាភាសាអង់គ្លេស)។

[41] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៩ (ជាភាសាអង់គ្លេស)។

[42] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៦០-៦១ (ជាភាសាអង់គ្លេស)។

ទុក និងដោយហេតុថាឯកសារទាំងនេះពុំមានដាក់សម្គាល់អត្តសញ្ញាណអ្នកនិពន្ធ។ ជាពិសេស ឯកសារទាំងនេះរួមទាំងឯកសារពាក់ព័ន្ធនឹងស្រុកត្រាំកក់[43]។

16. ជាការឆ្លើយតប សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការជំទាស់របស់ក្រុមមេធាវីការពារក្តីជាច្រើន គឺទាក់ទងនឹងតម្លៃ និងទម្ងន់ដែលមាននៅក្នុងឯកសារទាំងនេះ ជាជាងភាពអាចទទួលយកបាននៃឯកសារ[44]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា និងបានកត់សម្គាល់បន្ថែមទៀតថា ការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ គឺជាការជំទាស់ដែលអង្គជំនុំជម្រះបានសម្រេចនាពេលមុនរួចរាល់អស់ហើយ[45]។

17. នៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួន ក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងសារជាថ្មីអំពីការជំទាស់នាពេលមុនៗ ចំពោះការទទួលយកឯកសារទាំងឡាយណាដែលមិនបង្ហាញថាមានយថាភាព ឬបានបង្ហាញថាមានយថាភាព[46]។ ក្រុមមេធាវីការពារក្តីក៏បានកត់សម្គាល់ផងដែរថា ឯកសារចំនួន ៣៨ នៅក្នុងបញ្ជីឯកសារបឋមដែលមានឯកសារចំនួន ៥៤ (ដែលបានចែកជូននៅក្នុងសវនាការថ្ងៃ ២២ ខែ មករា ឆ្នាំ ២០១៣) មិនបានដាក់ឱ្យពិភាក្សាដេញដោលឡើយ ហើយក្រុមមេធាវីការពារក្តីបានជំទាស់ទៅនឹងឯកសារសរុបចំនួន ១៨០ ដែលបានបែងចែកជាប្រភេទខុសៗគ្នាមួយចំនួន[47]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងសារជាថ្មីអំពីការជំទាស់នាពេលមុនៗរបស់ខ្លួនចំពោះសៀវភៅ ខ្សែភាពយន្តឯកសារ ចម្លើយសារភាព របាយការណ៍នៃដីកាឱ្យស៊ើបសួរជំនួស និងឯកសារនានាដែលបានបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា[48]។ ជាសរុបមក ក្រុមមេធាវីការពារក្តីនេះបានបង្ហាញអត្តសញ្ញាណ

---

[43] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៦១-៦២ (ជាភាសាអង់គ្លេស)។

[44] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៤៨ (ជាភាសាអង់គ្លេស) កថាខណ្ឌ ៦៣-៧០។

[45] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៥២, ៥៣ (ជាភាសាអង់គ្លេស) (ដោយកត់សម្គាល់សេចក្តីសម្រេចលើឯកសារក្របខណ្ឌ និងសេចក្តីសម្រេចលើកទីពីរលើឯកសារ)។

[46] សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ អៀង សារី ទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា ទំព័រ ១។

[47] សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ អៀង សារី ទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា ទំព័រ ២-៤ (ជាភាសាអង់គ្លេស)។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៥៣-៥៦។ ឯកសារនៅសល់ចំនួន ១៦ មាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ឬ ត្រូវបានសម្រេចនាពេលមុនរួចហើយ។

[48] សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ ខៀវ សំផន ទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា ទំព័រ ៣-៤ (ជាភាសាអង់គ្លេស)។

ឯកសារចំនួន ៥៦ នៅក្រោមប្រភេទទាំងឡាយដែលក្រុមមេធាវីការពារក្តីនេះបានជំទាស់ រួមទាំងឯកសារលេខ D108/31.28 នៅក្នុងបញ្ជីដែលស្នើដោយ អៀង សារី ផងដែរ[49]។

18. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងអំពីសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សររបស់ខ្លួនជាថ្មីម្តងទៀត ហើយបានស្នើសុំថា ការជំទាស់ភាគច្រើនរបស់ក្រុមមេធាវីការពារក្តីគួរត្រូវច្រានចោលដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះបានច្រានចោលការជំទាស់ទាំងនេះពីមុនរួចរាល់អស់ហើយ[50]។

19. នៅក្នុងការជំទាស់ជាលាយលក្ខណ៍អក្សរចំពោះឯកសារថ្មីៗ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក្រៅពីរំលឹកឡើងវិញអំពីការជំទាស់របស់ខ្លួននាពេលមុន បានសន្និដ្ឋានថា ឯកសារទាំងនេះភាគច្រើនមិនអាចទទួលយកបានដោយផ្អែកលើមូលដ្ឋានថា មិនមានភាពពាក់ព័ន្ធ នៅក្រៅពីរយៈពេលដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ ផ្ទុយពីដីកាដំណោះស្រាយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលត្រូវបង្ហាញ មិនមានជាភាសាខ្មែរ មិនមានយថាភាព ទទួលបានតាមរយៈការធ្វើទារុណកម្ម ឬមិនសមស្របនឹងទទួលយកដោយហេតុថា អ្នកនិពន្ធឯកសារទាំងនេះពុំបានបង្ហាញអត្តសញ្ញាណ[51]។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការជំទាស់ទាំងនេះគឺជាការជំទាស់ដដែលៗ ឬមានលក្ខណៈទូទៅតែប៉ុណ្ណោះ[52]។

## ៤. សម្អាងហេតុ

### ៤.១. សេចក្តីផ្តើម

20. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង មានតែឯកសារទាំងឡាយណាដែលបានបំពេញជាបឋម នូវបទដ្ឋានពាក់ព័ន្ធ ភាពអាចជឿទុកចិត្ត និងយថាភាព ប៉ុណ្ណោះ ដែលអាចដាក់នៅ

---

[49] លិខិតពី ម៉េត ជូនចំពោះ ឌុច ឯកសារលេខ D108/31.28។

[50] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ អៀង សារី និង ខៀវ សំផន កថាខណ្ឌ ៣-៤ (ដោយដាក់បញ្ចូលចំណុចយោងនៃសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នាពេលមុនរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងឯកសារដែលត្រូវបានចាត់ទុកថាជាលិខិតឆ្លើយឆ្លងអន្តរជាតិ រួមទាំង របាយការណ៍សារព័ត៌មានអន្តរជាតិ ខ្សែវីដេអូ និងភាពពាក់ព័ន្ធនៃរបាយការណ៍ស្រុកត្រាំកក់។

[51] សេចក្តីជំទាស់របស់ ខៀវ សំផន ទៅនឹងឯកសារថ្មី កថាខណ្ឌ ២៦-៣០។

[52] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ ខៀវ សំផន ទៅនឹងឯកសារថ្មី កថាខណ្ឌ ៤០-៤៣។

ចំពោះមុខអង្គជំនុំជម្រះបាន។ នៅក្នុងសេចក្តីសម្រេចនាពេលមុនលើឯកសារ អង្គជំនុំជម្រះបានគូសបញ្ជាក់នូវគោលការណ៍ទូទៅដូចខាងក្រោម ស្តីពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក[53]៖

ក. ឯកសារទាំងអស់ដែលបានយោងនៅក្នុងផ្នែកទាំងប៉ុន្មាននៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងចំណុចអង្គហេតុនីមួយៗដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង ០០២/០១ ត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព)[54]។

ខ. ឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានទទួលការសន្មតថាបានបំពេញជាបឋមនៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព)។ ផ្អែកលើសក្ខីកម្មរបស់ប្រធាន និងអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់នៅក្នុងការទទួលបានឯកសារ ការធ្វើប័ណ្ណសារ និងការរក្សាទុកឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យមានភាពអាចជឿជាក់បាន ហើយអង្គជំនុំជម្រះពុំបានរកឃើញមូលដ្ឋានណាមួយដែលអាចសន្និដ្ឋានបានថា ឯកសារទាំងឡាយដែលមានប្រភពចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទំនងជាត្រូវបានកែសម្រួល ក្លែងបន្លំ ឬក្លែងក្លាយឡើយ[55]។

គ. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធពុំប្រើប្រាស់ការសន្មតអំពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព) សម្រាប់ឯកសារទាំងអស់ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ នោះទេ ដោយផ្អែកលើមូលដ្ឋានថា មិនមែនឯកសារទាំងអស់នៅក្នុងសំណុំរឿង០០១ មានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ឡើយ។ ទោះបីជាយ៉ាងនេះក្តី ភាពអាចជឿជាក់បានដែលត្រូវបានផ្តល់ទៅលើ

---

[53] *សូមមើលផងដែរ* ដីកាកំណត់កាលបរិច្ឆេទសវនាការលើកទីមួយលើឯកសារ។ សេចក្តីសង្ខេបសេចក្តីសម្រេចផ្ទាល់មាត់។ សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស ឯកសារលេខ E142/3 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើឯកសារថ្មី និងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ។

[54] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ២០។ *សូមមើលផងដែរ* សេចក្តីសង្ខេបសេចក្តីសម្រេចផ្ទាល់មាត់ កថាខណ្ឌ ៣ និងប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៨៥-៨៨ (ជាភាសាអង់គ្លេស)។

[55] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ២៨។

ឯកសារទាំងនេះក្នុងសំណុំរឿង០០១ គឺជាកត្តាមួយដែលត្រូវពិចារណានៅក្នុងការសម្រេចអំពីភាពស្របគ្នាជាមួយនឹងវិធាន ៨៧ នៃវិធានផ្ទៃក្នុង[56]។

ឃ. បញ្ហានានា នៅក្នុងចំណោមបញ្ហាផ្សេងៗទៀត ពាក់ព័ន្ធនឹងលទ្ធភាពអាចមើលយល់នៃឯកសារថតចម្លង ឬភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់ថតសម្លេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរដែលបានសង្ខេប គឺជាបញ្ហាពាក់ព័ន្ធនឹងទម្ងន់ដែលមាននៅក្នុងភស្តុតាងជាជាងភាពអាចទទួលយកបាននៃឯកសារទាំងនោះ អនុលោមតាមវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង[57]។

ង. មិនមានលក្ខខណ្ឌតម្រូវនៅក្នុងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក ថា ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវមានភាពពាក់ព័ន្ធតែចំពោះសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ទោះបីជាប្រភពនានាដូចជា សៀវភៅ របាយការណ៍វិភាគ ខ្សែភាពយន្តឯកសារ ឬអត្ថបទសារព័ត៌មានអាចទទួលយកបានក៏ដោយ ក៏ទម្ងន់សមស្របដែលមាននៅក្នុងឯកសារទាំងនេះ នឹងត្រូវធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះនៅក្នុងពេលមួយសមស្រប[58]។

ច. អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺនាពេលមុនរួចហើយនៅក្នុងយុត្តិសាស្ត្ររបស់ខ្លួន អំពីការប្រើប្រាស់ដោយមានកម្រិតបំផុតដែលអាចទាញចេញដោយស្របច្បាប់ពីភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម[59]។

ឆ. ការជំទាស់ដែលខ្វះមូលដ្ឋានជាក់លាក់គ្រប់គ្រាន់ថាតើហេតុអ្វីបានជាឯកសារជាក់លាក់ណាមួយ ឬប្រភេទឯកសារណាមួយ មិនអាចទទួលយកបាននោះ ត្រូវតែច្រានចោល[60]។

---

[56] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ៣៤។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៦៥-៦៦ (ជាភាសាអង់គ្លេស) (ដែលកត់សម្គាល់ថា អង្គជំនុំជម្រះបានសម្រេចដាក់នៅចំពោះមុខខ្លួនរួចហើយនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរជាក់លាក់នៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហេតុដូច្នេះច្រានចោលការជំទាស់របស់ក្រុមមេធាវីការពារក្តីទៅនឹងកំណត់ហេតុទាំងនេះ)។

[57] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ២១ និងកថាខណ្ឌ ៣០។

[58] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ២១(៤) និងកថាខណ្ឌ ៣១។

[59] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ២១(៥) (ដែលដកស្រង់ឯកសារលេខ E74 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ និងសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួននៅក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី ២០ និងថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩។

[60] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ កថាខណ្ឌ ២៣។ *សូមមើលផងដែរ* ដីកាកំណត់កាលបរិច្ឆេទសវនាការលើកទីមួយលើឯកសារ កថាខណ្ឌ ២។

ជ. ពាក់ព័ន្ធនឹងលទ្ធភាពបកប្រែលើឯកសារទាំងឡាយឱ្យទៅជាភាសាផ្លូវការរបស់ អ.វ.ត.ក ទាំងអស់នោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់រួចហើយថា ភាគីដែលស្នើសុំការបង្ហាញឯកសារនៅក្នុងពេលជំនុំជម្រះមានបន្ទុកធានាធ្វើយ៉ាងណាមានជាបីភាសាផ្លូវការឱ្យបានទាន់ពេលវេលា[61]។ ហើយ

ឈ. បញ្ហាចោទពាក់ព័ន្ធនឹងតម្លៃ និងទម្ងន់ដែលមាននៅក្នុងឯកសារទាំងនេះ មិនពាក់ព័ន្ធនឹងការវាយតម្លៃអំពីភាពស្របគ្នាជាមួយនឹងលក្ខខណ្ឌនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ តម្លៃ និងទម្ងន់ដែលមាននៅក្នុងឯកសារទាំងនេះ នឹងត្រូវយកមកពិចារណាដោយអង្គជំនុំជម្រះនៅពេលវាយតម្លៃលើភស្តុតាង និងត្រូវធ្វើជាមួយសាលក្រម[62]។

21. គោលការណ៍ពាក់ព័ន្ធ ដែលអនុវត្តចំពោះភាពអាចទទួលយកបាន និងលក្ខខណ្ឌស្តីពីការវាយតម្លៃលើឯកសារថ្មី និងកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដែលស្នើសុំដោយភាគី ទោះបីជាពុំមានសក្ខីកម្មរបស់អ្នកនិពន្ធក៏ដោយ មាននៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះផ្សេងទៀត និងអនុស្សរណៈស្តីពីការគ្រប់គ្រងសវនាការ[63]។ គោលការណ៍ទូទៅខាងក្រោមនេះមានភាពពាក់ព័ន្ធនៅក្នុងករណីនេះ៖

ក. នៅក្នុងស្ថានភាពមួយចំនួន សម្ភារៈ/ឯកសារ ដែលមិនស្ថិតនៅក្នុងសំណុំរឿងដែលត្រូវបានបញ្ជូនតាំងពីដំបូងមកអង្គជំនុំជម្រះសាលាដំបូង ក៏អាចដាក់នៅក្នុងសំណុំរឿង និងអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបានដែរ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមសំណើរបស់ភាគីណាមួយ។ ឧទាហរណ៍ មុនពេលចាប់ផ្តើមសវនាការ ភាគីអាចបញ្ចូលឯកសារ "ថ្មី" ទៅក្នុងបញ្ជីឯកសាររបស់ខ្លួនបាន (*មានន័យថា* ឯកសារទាំងឡាយដែល

---

[61] សេចក្តីសម្រេចលើឯកសារក្របខណ្ឌ, កថាខណ្ឌ ២១(៨)។ សេចក្តីសម្រេចលើកទីពីរលើឯកសារ កថាខណ្ឌ ១៦។ *សូមមើលផងដែរ* ឯកសារលេខ E223/2/6/1 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣។

[62] សេចក្តីសម្រេចលើកទីពីរលើឯកសារ, កថាខណ្ឌ ១៣។

[63] *សូមមើល ឧ.* សេចក្តីសម្រេចលើឯកសារថ្មី។ សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២១-២៥ និងកថាខណ្ឌ ៣០-៣១ (*សូមមើលផងដែរ* សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារលេខ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែប្រែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារលេខ E223) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E223/2។

មិនទាន់ស្ថិតក្នុងសំណុំរឿងនៅពេលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងនេះ) អនុលោមតាមវិធាន ៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង។ នៅពេលសវនាការចាប់ផ្តើម ភាគីក៏អាចស្នើសុំដាក់ភស្តុតាងថ្មីបានដែរ (*មានន័យថា* ភស្តុតាងដែលមិនទាន់មាននៅមុនពេលចាប់ផ្តើមសវនាការ) ដោយដាក់នូវសេចក្តីសន្និដ្ឋានដែលមានសម្អាងហេតុត្រឹមត្រូវស្របតាមលក្ខណៈវិនិច្ឆ័យ ដែលមានចែងនៅក្នុងវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង[64]។

ខ. ភស្តុតាងទាំងអស់ត្រូវតែស្របទៅតាមលក្ខណៈវិនិច្ឆ័យទូទៅសម្រាប់ការទទួលយកជាភស្តុតាងដែលមានចែងនៅក្នុងវិធាន ៨៧(៣)(ក)-(ង) នៃវិធានផ្ទៃក្នុង។ អាស្រ័យហេតុនេះ ឱកាសសម្រាប់ភាគីក្នុងការជំទាស់ទៅនឹងឯកសារទាំងឡាយអនុលោមតាមលក្ខណៈវិនិច្ឆ័យទាំងនេះ ក៏ជាបុរេលក្ខខណ្ឌមួយសម្រាប់ការទទួលឯកសារថ្មីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះដែរ[65]។ និង

គ. កំណត់ហេតុនៃការស្តាប់ចម្លើយមុនៗរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ឬសក្ខីកម្មដែលត្រូវបានស្តាប់នៅពេលសវនាការ អាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះព្រមពេលជាមួយនឹងភស្តុតាងដែលពួកគាត់បានផ្តល់នៅពេលសវនាការ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដ៏ទៃទៀត ដែលស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួនជាក់លាក់ ក៏អាចទទួលយកបានផងដែរ បើទោះជាអ្នកនិពន្ធទាំងនោះមិនបានមកផ្តល់សក្ខីកម្មនៅពេលសវនាការក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី កំណត់ហេតុជាលាយលក្ខណ៍អក្សរដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីបង្ហាញអំពីការប្រព្រឹត្ត និងអំពើរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (លើកលែងតែមានអញ្ញត្រកម្មតិចតួច) មិនអាចទទួលយកបានឡើយអនុលោមតាមវិធាន ៨៧(៣)(ឃ)នៃវិធានផ្ទៃក្នុង លើកលែងតែក្រុមមេធាវីការពារក្តីទទួលបានឱកាសដេញដោលជាមួយអ្នកនិពន្ធអត្ថបទទាំងអស់នេះនៅក្នុងតុលាការ[66]។

22. អង្គជំនុំជម្រះបានពិនិត្យឡើងវិញលើឯកសារនីមួយៗដែលភាគីបានដាក់មកចំពោះមុខអង្គជំនុំជម្រះ ហើយក៏បានពិចារណាលើរាល់ការជំទាស់ទាំងអស់ចំពោះឯកសារទាំងនេះ ដោយផ្អែកទៅលើ

---

[64] សេចក្តីសម្រេចលើឯកសារថ្មី កថាខណ្ឌ ២៧ និងកថាខណ្ឌ ២២។

[65] សេចក្តីសម្រេចលើឯកសារថ្មី កថាខណ្ឌ ១៨។

[66] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២២-២៥។

លក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលមានការពាក់ព័ន្ធ។

## ៤.២. ការជំទាស់របស់សហព្រះរាជអាជ្ញា

23. អង្គជំនុំជម្រះសាលាដំបូងសូមរំលឹកថា នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនាថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានទទួលយកនូវការជំទាស់ទៅនឹងសំណួរដែលពាក់ព័ន្ធនឹង ក៥ (ការងារសាងសង់នៅតាមព្រំដែនថៃចន្លោះឆ្នាំ ១៩៨៤-១៩៨៨) ដោយសារតែសំណួរទាំងនេះ មិនពាក់ព័ន្ធទៅនឹងអង្គហេតុនៃការជំនុំជម្រះសំណុំរឿង ០០២/០១ ឡើយ[67]។ ហេតុដូច្នេះ ឯកសារលេខ E131/1/13.11 (ពាក់ព័ន្ធនឹងផែនការសាងសង់ ក៥ ឆ្នាំ១៩៨៧) (កថាខណ្ឌ ១២(iv)) ត្រូវបានច្រានចោលដោយមិនមានភាពពាក់ព័ន្ធ។ អង្គជំនុំជម្រះក៏បានដកចេញនូវឯកសារ E131/1/13/12 (សៀវភៅដែលពាក់ព័ន្ធនឹងបញ្ហានយោបាយសហសម័យមួយចំនួននៅក្នុងប្រទេសកម្ពុជា) ឯកសារលេខ E131/1/13.2 (អត្ថបទ *Vanity Fair* ពាក់ព័ន្ធនឹងអ្នកនយោបាយមួយចំនួនរបស់ប្រទេសកម្ពុជា) និងឯកសារលេខ E131/1/13.10 (របាយការណ៍ឆ្នាំ ១៩៩៨ ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងប្រទេសកម្ពុជានិងប្រទេសថៃ) (កថាខណ្ឌ ១៣ (ii) និង (iii)) ដោយផ្អែកលើមូលដ្ឋានថា ឯកសារទាំងនេះក៏ពាក់ព័ន្ធនឹងហេតុការណ៍នានានៅក្រៅពីវិសាលភាពនៃដីកាដំណោះស្រាយសំណុំរឿង០០២/០១ ហេតុដូច្នេះ ឯកសារទាំងនេះពុំមានភាពពាក់ព័ន្ធឡើយ។

24. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា លិខិតទាំងបួនច្បាប់ដែលបានដាក់ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន (ឯកសារលេខ E190/2.5 ឯកសារលេខ E190/2.7 ឯកសារលេខ E190/2.18 និងឯកសារលេខ E190/2.19) មានភាពពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ពោលគឺទាក់ទងនឹងអត្តចរិករបស់ជនជាប់ចោទ ខៀវ សំផន និងតួនាទីរបស់គាត់ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លិខិតលេខ E190/2.5 បានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៣ នៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់អ្នកនិពន្ធអត្ថបទនេះ ក្នុងពេលសវនាការ។ ដូចដែលសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានថា ទោះបីជាលិខិតទាំងនេះលើកឡើងពីបញ្ហានានាដែលនៅក្រៅពីអត្តចរិករបស់ជនជាប់ចោទ និងត្រូវបានរៀបចំឡើងនៅក្រោយដំណាក់កាលស៊ើបអង្កេតក៏ដោយ ក៏លិខិតទាំងនេះពាក់ព័ន្ធនឹងបញ្ហានានាដែលនឹងត្រូវយកមកពិចារណានៅពេលវាយតម្លៃអំពីតម្លៃ និងទម្ងន់ដែលមាននៅក្នុងឯកសារទាំងអស់នេះ។ អង្គជំនុំជម្រះសម្រេចទទួល

---

[67] ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ២៦-២៧ (ជាភាសាអង់គ្លេស)។

យកលិខិតទាំងនេះ។ ហេតុដូច្នេះ ការជំទាស់របស់សហព្រះរាជអាជ្ញាចំពោះលិខិតទាំងនេះ (កថាខណ្ឌ ១៣(i)) ត្រូវបានច្រានចោល។

## ៤.៣. ការជំទាស់របស់ក្រុមមេធាវីការពារក្តី

25. ក្រុមមេធាវីការពារក្តីជំទាស់ទៅនឹងឯកសារមួយចំនួនដោយផ្អែកលើមូលដ្ឋាននៃភាពពាក់ព័ន្ធ។ ការជំទាស់ភាគច្រើនមិនមានមូលដ្ឋានជាក់លាក់ ហើយអង្គជំនុំជម្រះមានសិទ្ធិច្រានចោលការជំទាស់ទាំងនេះដោយផ្អែកលើមូលដ្ឋាននេះ (កថាខណ្ឌ ២០(ឆ))។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានពិនិត្យមើលឡើងវិញលើឯកសារទាំងអស់ដែលត្រូវបានជំទាស់ដោយផ្អែកលើមូលដ្ឋាននេះ ហើយបានវាយតម្លៃថា តើឯកសារទាំងនេះពាក់ព័ន្ធនឹងការបញ្ជាក់ការពិតនៅក្នុងសំណុំរឿង០០២/០១ ដែរឬទេ ហើយឯកសារទាំងនេះបានគោរពតាមវិធាន ៨៧(៣)(ក)នៃវិធានផ្ទៃក្នុងដែរឬក៏យ៉ាងណា។ ការជំទាស់របស់ក្រុមមេធាវីការពារក្តីភាគច្រើន (ជាឧទាហរណ៍ ការជំទាស់នៅក្នុងកថាខណ្ឌ ១៥(i), (ii), (v), (vii) និង (viii)) ក៏មានលក្ខណៈដូចគ្នាទៅនឹងអ្វីដែលពួកគេបានលើកឡើងនៅក្នុងសំណើមុនៗ ហើយដែលអង្គជំនុំជម្រះបានសម្រេចនៅក្នុងសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃឯកសារ និងត្រូវបានច្រានចោលដោយផ្អែកលើមូលដ្ឋានដូចបានចង្អុលបង្ហាញនៅក្នុងសេចក្តីសម្រេចនោះផងដែរ។

26. ពាក់ព័ន្ធនឹងរបាយការណ៍ស្តីពីដីកាចាត់ឱ្យស៊ើបសួរជំនួសដែលក្រុមមេធាវីការពារក្តី អៀង សារី ជំទាស់ (កថាខណ្ឌ ១៥ (vi)) អង្គជំនុំជម្រះកត់សម្គាល់ឃើញថា របាយការណ៍ស្តីពីដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានទទួលយកនាពេលមុនរួចហើយ ទាំងក្នុងសេចក្តីសម្រេចលើឯកសារក្របខណ្ឌ និងសេចក្តីសម្រេចលើកទីពីរលើឯកសារ។ អង្គជំនុំជម្រះពិចារណាឃើញថា ឯកសារទាំងនេះ ជាប្រភេទឯកសារ ដែលអាចដកចេញបាន អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ទោះបីជាយ៉ាងណាក៏ដោយ ការជំទាស់ទាំងអស់ពាក់ព័ន្ធនឹងភាពល្មៀងនៃខ្លឹមសារឯកសារទាំងនេះ នឹងត្រូវយកមកពិចារណាដោយអង្គជំនុំជម្រះនៅពេលវាយតម្លៃអំពីតម្លៃនិងទម្ងន់ដែលមាននៅក្នុងឯកសារទាំងនេះ នៅពេលវាយតម្លៃលើភស្តុតាងទាំងអស់។ ពាក់ព័ន្ធនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះការទទួលយកប្រវត្តិរូបរបស់ ឡុង នរិន្ទ (LONG Norin) អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១១ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងឯកសារនេះនៅក្នុងពេលផ្តល់សក្ខីកម្មដោយសាក្សីរូបនេះ។

## ៤.៤. សេចក្ដីសន្និដ្ឋាន

27. ក្រោយពីបានពិនិត្យមើលឯកសារទាំងអស់ ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងអៀង សារី អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនោះ បានបំពេញជាបឋម នូវបទដ្ឋានពាក់ព័ន្ធ និងភាពអាចជឿទុកចិត្ត (រួមទាំងយថាភាព) លើកលែងតែឯកសារចំនួន ១១។ ហេតុដូច្នេះ ឯកសារទាំងអស់នេះបានបំពេញនូវលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបានដូចមានចែងនៅក្នុងវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ដូចគ្នានេះដែរ អង្គជំនុំជម្រះយល់ឃើញថា ឯកសារថ្មីទាំងអស់បានបំពេញនូវលក្ខណៈវិនិច្ឆ័យនៃវិធានផ្ទៃក្នុងផងដែរ លើកលែងតែឯកសារមួយចំនួនតូចប៉ុណ្ណោះ។ ហេតុដូច្នេះ ឯកសារទាំងនេះត្រូវបានផ្ដល់លេខសំគាល់ E3 និងដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ទោះបីជាការជំទាស់ទាំងអស់ចំពោះឯកសារទាំងនេះត្រូវបានលើកឡើងនៅក្នុងពេលសវនាការក៏ដោយ ក៏អង្គជំនុំជម្រះនឹងពិចារណានៅពេលថ្លឹងថ្លែងអំពីតម្លៃ និងទម្ងន់ដែលមាននៅក្នុងឯកសារនីមួយៗ ជាមួយនឹងសាលក្រមតែម្ដង។

28. ដើម្បីឱ្យងាយស្រួលយោង អង្គជំនុំជម្រះបានដាក់បញ្ចូលឯកសារទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធចំនួន ៦ នៃសេចក្ដីសម្រេចនេះ៖ ឧបសម្ព័ន្ធ ក (រួមមានឯកសារទាំងអស់នៅក្នុងបញ្ជីឯកសារដំបូងរបស់សហព្រះរាជអាជ្ញា) ឧបសម្ព័ន្ធ ខ (ឯកសារទាំងអស់នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទីមួយ) ឧបសម្ព័ន្ធ គ (ឯកសារទាំងអស់ដែលបានស្នើឡើងនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទីពីរ) ឧបសម្ព័ន្ធ ឃ (ឯកសារទាំងអស់នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ) ឧបសម្ព័ន្ធ ង (ឯកសារទាំងអស់នៅក្នុងបញ្ជីឯកសាររបស់ អៀង សារី) និងឧបសម្ព័ន្ធ ច (ឯកសារថ្មី)។

**ផ្អែកតាមសម្អាងហេតុដូចខាងលើនេះ អង្គជំនុំជម្រះសាលាដំបូង៖**

**សម្រេចថា** ឯកសារខាងក្រោមត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងផ្ដល់លេខសម្គាល់ E3 ដល់ឯកសារទាំងនេះ។

i. ឯកសារលេខ D366/7.1.72 (ផ្ដល់លេខសម្គាល់ E3/4603)។

ii. ឯកសារលេខ D243/2.1.16 (ផ្ដល់លេខសម្គាល់ E3/4604)។ និង

iii. ឯកសារលេខ D366/7.1.820 (ផ្ដល់លេខសម្គាល់ E3/4605)។

**សម្រេចថា** ឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ ក ដល់ ឧបសម្ព័ន្ធ ច នៅក្នុងសេចក្តីសម្រេចនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ លើកលែងតែឯកសារចំនួន ១៤ ដែលនឹងត្រូវធ្វើការផ្តល់អត្តសញ្ញាណ និងបញ្ជាក់លក្ខណៈជាក់លាក់នាពេលក្រោយនៅក្នុងឧបសម្ព័ន្ធនីមួយៗនៃឧបសម្ព័ន្ធទាំងអស់នេះ។

**រំលឹកថា** តម្លៃ និងទម្ងន់ដែលមាននៅក្នុងភស្តុតាងទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលជាបច្ច័យនៃសេចក្តីសម្រេចនេះ នឹងត្រូវយកមកពិចារណាសម្រេចដោយអង្គជំនុំជម្រះនៅក្រោយពេលបញ្ចប់សវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ និងត្រូវធ្វើជាមួយសាលក្រម។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**